មាគ៌ា នៃ ការកែទម្រង់ សីលធម៌

La voie de la réforme morale

លោក Edgar Morin សង្គមវិទូ និង ទស្សនៈវិទូ បារាំងសែស ដ៏ល្បីមួយរូបក្នុងពិភពលោក បានសរសេរ អំពី មាគ៌ា នៃ ការកែទម្រង់សីលធម៌[1]។ ដោយអាស្រ័យអំណាចនៃគុណធម៌ នៃ នរត្រីមូរតី[2] : បុគ្គល/សង្គម/ពួជមនុស្ស, បើតាម លោក ម្ហ្ស៊ាង ត្រូវយល់ដូច្នេះថា សីលធម៌ មាន ទិសភាគបីយ៉ាង : សីលធម៌ នៃ បុគ្គល, សីលធម៌ នៃពលរដ្ឋ និង សីលធម៌ នៃក្រុមមនុស្ស។

សីលធម៌ នៃបុគ្គល

សីលធម៌នេះ គោងតែ បញ្ចូល ទៅក្នុង សតិសម្បជញ្ញៈ និង អត្តភាព នៃបុគ្គលនិមួយៗ ក្នុងគោលការណ៍ នៃ ស្វ័យពិនិត្យ ជាអចិន្ត្រៃយ៍ ព្រោះ មនុស្ស តែងតែ ជោកជាំ និង ការ ខ្ជិនឯង មិនលែងឡើយ។ ហើយនៅក្នុងអារម្មណ៍និយមថាខ្លួនជាមនុស្ស ដ៏ផ្ញើម នាំអោយ អនុស្សរវីយ៍របស់ខ្លួន ភ្ជង់តម្រូវទៅរកតែ អត្ត ប្រយោជន៍ផ្ទាល់ខ្លួន ហើយនាំអោយមាន ចក្ខុវិស័យ ចំពោះខ្លួនឯង និង ចំពោះអ្នកផង ច្រើននាំខូចអារម្មណ៍។ ដូច្នេះ បើ មនុស្សយើង ចង់ធ្វើ កំណែទម្រង់សីលធម៌ មនុស្សយើងមិន អាចសំជ័យនូវ ស្វ័យពិនិត្យ និង ស្វ័យទិតៀន ដើម្បី លុបបំបាត់

[1] La voie – Edgar Morin, édition Fayard.

[2] នរត្រីមូរតី ; trinité humaine.

នូវ គោលគំនិតនោះ។ តែថា មនុស្សយើង តែងតែមាន ជំនឿ ថា ដំណោះស្រាយ នៃ ទុក្ខនៃសតិ និង ទុក្ខនៃសីលធម៌ របស់ ខ្លួន វាអាស្រ័យដាច់មុខ នៅលើ អ្នកផង, អ្នកចិត្តតិកិច្ច ឬ អ្នកចិត្តវិភាគ។ មែនពិតហើយថា ការសេពគប់នឹង អ្នកផង វា ជា ការចាំបាច់ ដើម្បីឲយើង អាចស្គាល់ខ្លួនឯង ប៉ុន្តែ ស្វ័យពិនិ ត្យ ដោយ អាភោគចិត្ត លើខ្លួនឯង ផង វាកាន់តែនាំឲយើង អាចស្គាល់ខ្លួនឯងច្បាស់ ក៏ស្គាល់ កង្វះ និង ទុព្វលភាព របស់ ខ្លួនឯង។ មនុស្សលោក អាចមាន ការយល់ដឹង អំពីទុក្ខ អ្នកផង មាននៅក្នុងរឿង ប្រលោមលោក, ល្ខោន, កុន តែនៅ ក្នុងជីវិតទូទៅ មនុស្សលោក តែងតែបាត់ សមត្ថភាព នៃ ការ យល់ដឹង អំពី ទុក្ខភ័យ របស់អ្នកផង ព្រោះ មនុស្សយើង តែង តែចែកដាច់ ជីវិតផ្ទាល់ខ្លួន ពី ជីវិតអ្នកផង និង អ្វី ជា រឿង ពិត ពី អ្វី ដែលជារឿងប្រឌិត។

ម្លោះហើយ ការកែទម្រង់ នៃសីលធម៌ ក៏ត្រូវ បណ្តុះបណ្តាល ជា អាទិភាព នូវ ស្វ័យពិនិត្យ ជាអចិន្ត្រៃយ៍ និង សម្បទា នៃ ការ យល់ដឹង អំពី អ្នកផង។ ការកែទម្រង់នោះ វាត្រូវធ្វើរួមគ្នា ពិត ប្រាកដ ជាមួយនឹង ការកែទម្រង់ នៃ ការអប់រំ និង ជីវិតផ្ទាល់ ខ្លួនដែរ ហើយ ត្រូវធ្វើរួមទៅទៀត ជាមួយនឹង ការកែទម្រង់ ផ្សេងៗទៀតផង។

សីលធម៌ នៃពលរដ្ឋ

សីលធម៌ នៃពលរដ្ឋ នៅក្នុងសង្គម ដែល វាអាស្រ័យ ទៅលើ សិទ្ធិ នៃ ពលរដ្ឋ ត្រូវ រ៉ាប់រង នូវ ការណីយកិច្ចរួម នៃ ប្រជាពលរដ្ឋ។

សីលធម៌ នៃក្រុមមនុស្ស

ដូចជា សីលធម៌សកល ដែលពាក់ព័ន្ធនឹង មនុស្ស វាហាក់ដូចជា រ្ត្ត្ត

សារ នៃ នរអត្តនោម័ត[7] ដូចយ៉ាង ទស្សនៈ របស់មនុស្ស ស្តីពី ស្វ័យការពោលអះអាង នៃ មជ្ឈត្តនិយម[8] នៅក្នុងពាក្យ ‹អញ› ដែល ជា ពាក្យ សំរាប់ តែខ្លួនឯងម្នាក់គត់ គឺថា គ្មាន នរណា មួយទៀត អាច និយាយ អំពី អញ ជំនួសខ្លួនបាននោះឡើយ ឬ មមំការ[9]។ ក្នុងន័យនេះ ជា មនុស្ស មាន -គោលការណ៍ នៃមជ្ឈ ត្តនិយម - ទុកជា អាទិភាពសំរាប់ខ្លួនឯងលើអ្នកផង ឬ លើ អ្វីៗទាំងអស់។ ប៉ុន្តែ មនុស្ស ព្រនាក់ នូវ គោលការណ៍ នៃ ភាវ: ‹‹ យើង ›› (nous) ដែលជា គោលការណ៍ ក្លួនមនុស្ស បញ្ចូល ទៅ ក្នុង ការទំនាក់ទំនង នៃសហគមន៍ និង ការរាប់អាន អ្នកផង ហើយនឹង ‹ជារបស់យើង› (nôtre) (ត្រួសារ, មិត្ត, មាតុភូមិ) ហើយ តាំងពីកំណើតមក មនុស្សលោក តែងតែមាន ជីវសេច ក្តីត្រូវការ នៃ ប្រតិព័ទ្ធនឹង ទារក ដែលជាចំណង ជា មនោ វិញ្ញាណ នៃ សេចក្តីស្នេហា រវាង មនុស្សនឹងមនុស្ស។ គោលការ ណ៍ នៃ បូរណកម្ម[10] នេះ អាចជំរុញ មនុស្ស អោយធ្វើ ពលកម្ម ដល់ ជីវិត សំរាប់ ‹យើង› នោះ។ គេអាចធ្វើការសន្និដ្ឋានបានថា មនុស្សលោក មាន ចរិតលក្ខណ: ពីរ គឺ ‹អញ› និង ‹យើង›។ ‹ អញ› ជម្រុញ មនុស្ស អោយ អ្នកផង ធ្វើពលកម្ម សំរាប់ខ្លួន រីឯ ‹យើង› វិញ ជម្រុញ មនុស្ស អោយធ្វើពលកម្ម សំរាប់អ្នកផង

---

[7] ខ្លឹម នៃ នរអត្តនោម័ត ; le cœur de subjectivité humaine.

[8] មជ្ឈត្តក: ; égocentrique. Egocentrisme ; មជ្ឈត្តនិយម, និយមថាខ្លួនជា មនុស្សដ៏ផ្ទើម។

[9] មមំការ (មមង្ការ) : សេចក្តីយល់ប្រកាន់ថាជារបស់ផងអញ។

[10] គោលការណ៍ នៃ បូរណកម្ម ; principe d'intégration.

មាគ៌ា នៃ ការកែទម្រង់ សីលធម៌

នៅក្នុងអារម្មណ៍ នៃ បរទត្តភាព[11], មិត្តភាព និង សេចក្តីស្នេហា។ អរិយធម៌ នៃ មនុស្សលោក តែងតែទន់ទៅរក មជ្ឈត្តនិយម។ តែថា គំនិត នៃ បរទត្តភាព និង សាមគ្គីភាព ជា មនោវិញ្ញាណ នៃ មនុស្សលោក តែ ចិត្ត វា រសូរ ហាមវា មិនអោយ សំដែងចេញ និង ចិត្ត មាន មោនភាព[12]។ ដូច្នេះ បញ្ហាត្ត និង ការ:ស្ងៀម នេះឯង ដែលត្រូវ ឧទ្ទឹបវា តាមការកែទម្រង់ សីលធម៌ ដូចបានរៀបរាប់ខាងលើនេះ។

នៅក្នុងអត្ថបទនេះ យើងមិនលើកយក ចរិតអកុសលស របស់ខ្មែរយើងមក ពិពណ៌នាយ៉ាងពិស្តា នោះទេ តែយើង ផ្ញើអនុសាស អោយខ្មែរណា ចង់ដឹងអំពី គុណវិបត្តិ នៃ ចរិតខ្មែរ សូមអានសៀវភៅ របស់ លោក ប៉ុណ្ណចន្ទ ម៉ុល មានចំណងជើង ថា ‹ចរិតខ្មែរ› ក្នុងនោះ អ្នកនិពន្ធ បានអធិប្បាយវា យ៉ាងក្បោះក្បាយ ជា ការរិះគន់ស្ថាបនា ដើម្បី ទុកជា មេរៀន ដល់ កូនខ្មែរ ជំនាន់ក្រោយ។ ចំណង់ របស់ អ្នកនិពន្ធ គឺ ផ្សាយ គំនិត ដើម្បីជួយរំលឹកគ្នាអោយយល់ នូវមាគ៌ាល្អអាក្រក់ គ្រប់ យ៉ាង ដើម្បីអោយបានស្គាល់ សេចក្តីល្អ សុខចំរើនក្នុងជីវិតម្នាក់ៗ រហូតដល់សង្គមជាតិ។

---

[11] បរទត្តភាព ; altruisme ; អ្នកដែលឃើញប្រយោជន៍អ្នកដទៃ។

[12] មោនភាព : ការ:ស្ងៀម។